# ការបន្សុំកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការបន្សុំទៅនឹងប្រភេទនៃការប្រែប្រួលអាកាសធាតុ៖ អនុសាសន៍គោលនយោបាយបឋមមួយចំនួន

លទ្ធផលនៃការសិក្សាមួយបានបង្ហាញថាសកម្មភាពនៃការបន្សុំនាពេលបច្ចុប្បន្នពុំបានគិតគូរឱ្យបានដិតដល់អំពីផលប៉ះពាល់នៃភាពតានតឹងនៃកម្តៅលើផលិតភាពពលកម្ម។ ដូចនេះ ការយកចិត្តទុកដាក់បន្ថែមគួរផ្តោតលើវិធានការការពារចង្វាក់ផ្គត់ផ្គង់ និងកម្មករពីភាពតានតឹងនៃកម្តៅជាពិសេសក្នុងវិស័យកសិកម្ម សំណង់ និងកម្មន្តសាល។ វិស័យឯកជនដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហានេះ ខណៈរដ្ឋាភិបាលជាអ្នកផ្តល់ការគាំទ្រផ្នែកគោលនយោបាយនិងការវិនិយោគសាធារណៈ

បើទោះបីជាយ៉ាងណា ជាញឹកញាប់គេតែងតែសន្មត់ថាវិស័យកសិកម្មនឹងមានសារៈសំខាន់តិចតួចសម្រាប់សេដ្ឋកិច្ចក្នុងរយៈពេលវែង ភស្តុតាងចេញពីការសិក្សាបានបង្ហាញថាចំណែកនៃវិស័យកសិកម្មនិងពិតជាមាននិន្នាការថមថយប៉ុន្តែវានៅតែមានសារៈសំខាន់ដែលទាមទារឱ្យមានគោលនយោបាយបន្សុំសំដៅជំរុញកំណើនប្រកបដោយបរិយាប័ន្ន និងសមធម៌

ដូចនេះ វាពិតជាចាំបាច់ក្នុងការពង្រឹងភស្តុតាងស្តីពីផលប៉ះពាល់នៃការកើនឡើងនីវ៉ូទឹកសមុទ្រ ដោយសារភស្តុតាងពីមុនមកបានពន្យល់ថា ផលប៉ះពាល់ទាំងនេះអាចមានកម្រិតខ្ពស់ជាងការខូចខាតដែលបណ្តាលមកពីទឹកជំនន់និងខ្យល់ព្យុះ ដែលនៅក្នុងនោះការឆ្លើយតបនឹងកំណើននីវ៉ូទឹកសមុទ្រនេះ មិនទាន់ផ្តល់អាទិភាពឱ្យបានគ្រប់គ្រាន់ក្នុងការអន្តរាគមន៍នាពេលបច្ចុប្បន្ននៅឡើយ

ក្នុងវិស័យជាច្រើន ការរៀបចំគោលនយោបាយសាធារណៈនឹងទាមទារឱ្យមានការសិក្សាជាក់លាក់បន្ថែមទៀត។ ការសិក្សានេះ រួមមាន ការវិភាគអំពីថាតើក្រុមមនុស្សងាយរងគ្រោះផ្សេងៗនឹងរងផលប៉ះពាល់ដោយរបៀបណា? ផលប៉ះពាល់ដោយសារកំណើននីវ៉ូទឹកសមុទ្រ និងជម្រើសបច្ចេកវិទ្យានានាដើម្បីដោះស្រាយផលប៉ះពាល់លើផលិតភាពពលកម្ម។

ការផ្តោតអាទិភាពជាចម្បងលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលទប់នឹងអាកាសធាតុដើម្បីជៀសវាងការខូចខាតលើទ្រព្យសម្បត្តិពិតជាសមស្រប និងត្រឹមត្រូវ។ ការវិភាគអំពីប្រសិទ្ធភាពចំណាយសម្រាប់វិធានការទាំងនេះពិតជាចាំបាច់ត្រូវតែធ្វើការផ្ទៀងផ្ទាត់ឱ្យបានសមស្របក្នុងដំណាក់កាលនៃការតាក់តែងគម្រោងដំបូង និងត្រូវធ្វើប្រសើរឡើងជាលំដាប់ ដូចជា តាមរយៈការពង្រឹងដំណើរការវាយតម្លៃគម្រោងសម្រាប់ថវិកាវិនិយោគរបស់រដ្ឋ។


**គាំទ្រដោយ៖**

CAMBODIA CLIMATE CHANGE ALLIANCE

Implemented by: Ministry of Environment

Supported by: European Union, UNDP, SWEDEN

GOVERNANCE OF CLIMATE CHANGE FINANCE TO ENHANCE GENDER EQUALITY IN ASIA PACIFIC www.CFADE.org


## ម៉ូដែលស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ច (GEGIM) ការកសាងម៉ូដែលមួយឱ្យសមស្របសម្រាប់កម្ពុជា

ម៉ូដែល CEGIM ត្រូវបានបង្កើតឡើងតាមរយៈការប្រឹក្សាយោបល់ជាមួយក្រសួង - ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយគិតគូរលើតម្រូវការ និងឧបសគ្គជាក់លាក់សម្រាប់ប្រទេសកម្ពុជា

ម៉ូដែលនេះមានលក្ខណៈសាមញ្ញ និងតម្លាភាព ដែលដំណើការលើ spread sheet ដែលអ្នកទូទៅ អាចងាយយល់

ម៉ូដែល CEGIM ប្រើប្រាស់ទម្រង់សំខាន់ៗមួយចំនួននៃម៉ូដែលផ្សេងៗទៀត ដែលត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់វាយតម្លៃពីផលប៉ះពាល់សេដ្ឋកិច្ចដោយសារការប្រែប្រួលអាកាសធាតុ

ម៉ូដែលនេះត្រូវបានអនុវត្តដើម្បីទាញយកលទ្ធផលដោយប្រើប្រាស់ទិន្នន័យពីអតីតកាលចំនួន ២៣ឆ្នាំ ដែលភាគច្រើនចេញពីគណនេយ្យជាតិ

**CEGIM ៣ ប្រភេទ**

ប្រភេទទាំងបីនៃផលប៉ះពាល់ដែលត្រូវបានដាក់បញ្ចូលក្នុងម៉ូដែល CEGIM៖ ម៉ូដែល CEGIM ដាក់បញ្ចូលនូវការបាត់បង់ និងការខូចខាតដោយផ្ទាល់៣ប្រភេទក្នុងទម្រង់ដូចខាងក្រោម៖

- ✓ ការបាត់បង់ចំណូលដែលនឹងកាត់បន្ថយផលិតផលក្នុងស្រុកសរុប (ផសស) ក្នុងឆ្នាំដែលកើតឡើង ប៉ុន្តែវាមិនមានផលប៉ះពាល់ដោយផ្ទាល់លើ (ផសស) ក្នុងឆ្នាំបន្ទាប់ទេ
- ✓ ឥទ្ធិពលនៃភាពតានតឹងនៃកំដៅ និងសុខភាពកាត់បន្ថយ (ផសស) តាមរយៈការកាត់បន្ថយផលិតភាពពលកម្ម
- ✓ ការខូចខាតទ្រព្យសម្បត្តិដោយសារតែព្រឹត្តការណ៍ធ្ងន់ធ្ងរ និងកំណើននីវ៉ូទឹកសមុទ្រកាត់បន្ថយស្តុកមូលធន
- ✓ ការកាត់បន្ថយ (ផសស) ក្នុងឆ្នាំបច្ចុប្បន្ននិងធ្វើអោយ (ផសស) នាពេលអនាគតថយចុះដោយប្រយោលតាមរយៈការកាត់បន្ថយការវិនិយោគ

ក្រាហ្វិច ១ គ្រប់ខ័ណ្ឌនៃម៉ូដែល (CEGIM)




- ម៉ូដែល CEGIM បញ្ចូលនូវភស្តុតាងល្អៗ ដែលមានជាច្រើនដែលពាក់ព័ន្ធនឹងការបាត់បង់ និងការខូចខាតពីការប្រែប្រួលអាកាសធាតុ

| ប្រភេទបាត់បង់ និងខូចខាត | ប្រភពទិន្នន័យ |
|---|---|
| ការបាត់បង់ប្រាក់ចំណូល | ការស្រាវជ្រាវ ករណីសិក្សា ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ |
| ផលិតភាពពលកម្ម | ការសិក្សាសរីរសាស្ត្រ (Physiological studies) |
| ការបាត់បង់ទ្រព្យសម្បត្តិ | ការវាយតម្លៃការខូចខាតដោយទឹកជំនន់ រាំងស្ងួត និងព្យុះ ម៉ូដែលនៃកំណើននីវ៉ូទឹកសមុទ្រ |

- ម៉ូដែល CEGIM អាចត្រូវបានធ្វើឱ្យប្រសើរឡើងបន្ថែមទៀត ជាមួយនឹងទម្រង់ថ្មី ដូចជា ផលប៉ះពាល់គោលនយោបាយស្តីពីការវិនិយោគឯកជន ឬបែងចែកផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យនិងក្រុមមនុស្សក្នុងសង្គមផ្សេងៗគ្នា។



# ដំណោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា

ម៉ូដែលមួយដែលសមស្របត្រូវបានបង្កើតដើម្បីប៉ាន់ប្រមាណផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ចកម្ពុជា និងកំណត់អាទិភាពនៃអន្តរាគមន៍សំខាន់ៗដើម្បីការពារកំណើនសេដ្ឋកិច្ចពីផលប៉ះពាល់ទាំងនេះ។

## ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ច



### ផលប៉ះពាល់សំខាន់ៗ លើសេដ្ឋកិច្ច

ក្រោមសេណារ៉ូចំបង (Headline Projection) បានសន្មត់ថាសីតុណ្ហភាពសាកលនឹងរក្សាកំណើននៅក្រោម២អង្សាសេនៅឆ្នាំ២១០០[1] ប្រសិនបើប្រទេសកម្ពុជារក្សាការវិនិយោគកម្រិតបច្ចុប្បន្នលើសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នោះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនឹងកាត់បន្ថយផលិតផលក្នុងស្រុកសរុប (GDP) ២,៥ភាគរយនៅឆ្នាំ២០៣០ និង ៩,៨ភាគរយនៅឆ្នាំ២០៥០។ ស្របពេលនេះដែរ អត្រាកំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំនឹងត្រូវកាត់បន្ថយជាមធ្យមចំនួន ០,៣ភាគរយ រវាងឆ្នាំ២០១៦ និង ២០៥០ (ចន្លោះពី៦,៩% ទៅ ៦,៦%) ហើយនឹងពន្យាពេលមួយឆ្នាំនៃការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

### ផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០៥០នឹងទាបជាង៩,៨%




[1] សេណារ៉ូ RCP ៤,៥ របាយការណ៍វាយតម្លៃលើកទី៥ របស់ក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC), ដោយឆ្លើយតបទៅនឹងកំណើនសីតុណ្ហភាពមធ្យម ១,៨អង្សាសេនៅឆ្នាំ២១០០។

វិស័យកសិកម្ម គឺជាវិស័យដែលរងផលប៉ះពាល់ខ្លាំងជាងគេបំផុតក្នុងរយៈពេលខ្លីប៉ុន្តែការធ្លាក់ចុះផលិតភាពកម្លាំងពលកម្ម និងការខូចខាតទ្រព្យសម្បត្តិដោយសារតែការប្រែប្រួលអាកាសធាតុនិងធ្វើឱ្យប៉ះពាល់គ្រប់វិស័យទាំងអស់ដែលក្នុងនោះវិស័យឧស្សាហ៍កម្មនិងរងផលប៉ះពាល់ខ្លាំងជាងគេ។

### ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើសេដ្ឋកិច្ចតាមវិស័យ និងប្រភេទនៃផលប៉ះពាល់ (ភាគរយនៃការធ្លាក់ចុះនៃកំណើនផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០៥០)




## ការការពារកំណើនសេដ្ឋកិច្ចពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ



នៅពេលដែលយើងមិនអាចបញ្ចៀសការបាត់បង់ និងការខូចខាតពីការប្រែប្រួលអាកាសធាតុក្នុងលក្ខណៈជាប្រសិទ្ធភាពចំណាយ ការស្រាវជ្រាវអន្តរជាតិបានស្នើឡើងថា "ការបាត់បង់ជាងពាក់កណ្តាលអាចជៀសវាងបានតាមរយៈគោលនយោបាយបន្សាំឱ្យបានខ្លាំងក្លា"។




ប្រសិនបើបានរក្សាកម្រិតចំណាយបច្ចុប្បន្នលើការបន្សាំការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជានឹងជួយបញ្ចៀសផលប៉ះពាល់បាន ៣៣% នៅឆ្នាំ២០៥០។

ពង្រឹងគោលនយោបាយបន្សាំនឹងការប្រែប្រួលអាកាសធាតុអាចជួយបញ្ចៀសផលប៉ះពាល់រហូតដល់៦៦% នៅឆ្នាំ២០៥០។

ទោះបីយ៉ាងណា ផលប៉ះពាល់សេដ្ឋកិច្ចបានកើនឡើងយ៉ាងពិតប្រាកដជាយូរណាស់មកហើយ ប្រសិទ្ធភាពនៃការចំណាយលើការបន្សាំបានកើនឡើងជាបន្តបន្ទាប់ជាយូរមកហើយដែរ និងបានជួយដោះស្រាយកំណើនមួយចំណែកពីផលប៉ះពាល់នេះ។

ម៉ូដែលបង្ហាញថា ការពង្រឹងគោលនយោបាយបន្សាំក្នុងប្រទេសកម្ពុជាអាចបញ្ចៀសច្រើនជាងពាក់កណ្តាលនៃផលប៉ះពាល់ដែលកំពុងបន្តដោយគ្មានការកាត់បន្ថយធនធានជំនួយចំពោះសកម្មភាពអភិវឌ្ឍតាមទម្លាប់កន្លងទៅ។




សេណារ៉ូ "បន្សាំកម្រិតខ្ពស់" ដោយរួមបញ្ចូលការបង្កើនការចំណាយលើការបន្សាំ (រួមទាំងហិរញ្ញប្បទានអន្តរជាតិ) គោលនយោបាយថ្មីៗ ដើម្បីលើកទឹកចិត្តវិស័យឯកជនក្នុងការបន្សាំ (ជាពិសេស ផលិតភាពពលកម្ម) និងមធ្យោបាយដើម្បីកែលម្អប្រសិទ្ធភាពតម្លៃ (ជាពិសេស ហេដ្ឋារចនាសម្ព័ន្ធដែលទប់នឹងអាកាសធាតុ)។ ក្រោមសេណារ៉ូនេះ អត្រាកំណើនចំណូលក្នុងស្រុកសរុបមធ្យមប្រចាំឆ្នាំគួរតែពី ៦,៦% ទៅ ៦,៨%។